អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## ការបង្ហាញភស្តុតាងក្នុងសវនាការជំនុំជម្រះក្តីរបស់ឌុច បានបញ្ចប់

សហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់រួចហើយទៅលើភស្តុតាងដែលពួកគេចង់បញ្ចូលទៅក្នុងសំណុំរឿងលេខ០០១ ប្រឆាំងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច នាថ្ងៃនេះ។ សវនាការបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការទទួលយកភស្តុតាងទាំងនោះ អាចនឹងត្រូវប្រព្រឹត្តធ្វើឡើងនៅមុនពេលសវនាការសម្រាប់ស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលនឹងចាប់ផ្តើមនៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

ចាប់តាំងពីពេលចាប់ផ្តើមនៃសវនាការលើអង្គសេចក្តីនាថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការសរុបចំនួន ៧២ ថ្ងៃ។ ក្នុងកំឡុងពេលនេះ សាក្សីជាអ្នកជំនាញចំនួន ៩ នាក់ សាក្សីលើអង្គហេតុចំនួន ១៧ នាក់ សាក្សីលើអត្តចរិត ចំនួន ៧ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ នាក់ បានផ្តល់សក្ខីកម្ម។

អ្នកទស្សនាសរុបចំនួន ២៣ ៧៤២ នាក់ បានតាមដានដំណើរការជំនុំជម្រះក្តីនៅក្នុងសាលសវនាការ ដែលក្នុងនោះគិតជាមធ្យមមានចំនួន ៣៣០ នាក់ ក្នុងមួយថ្ងៃ។

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីប្រចាំថ្ងៃ ក៏ដូចជាឯកសារផ្សេងៗទៀតដែលបង្ហាញនៅក្នុងសាលសវនាការ អាចស្វែងរកបាននៅក្នុងគេហទំព័រ

http://www.eccc.gov.kh/english/caseInfo001.aspx

រូបថតស្តីពីដំណើរការនីតិវិធីប្រចាំថ្ងៃអាចស្វែងរកបាននៅក្នុងគេហទំព័រ
http://www.flickr.com/photos/krtribunal/

សម្រាប់រូបថតទាំងនេះ អ្នកសារព័ត៌មានទាំងអស់អាចប្រើប្រាស់បានតាមសេចក្តីត្រូវការ ប៉ុន្តែគួរតែបញ្ជាក់ថារូបថតទាំងនេះផ្តល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**


លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
ទូរសារលេខ +855 (0) 23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក ឌីម សុវណ្ណារ៉ុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
ទូរសារលេខ +855 (0) 23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814
សារអេឡិចត្រូនិច olsen@un.org

លោកស្រី យុក្ខ មេដា
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ: +855 (0) 12 488 319
ទូរស័ព្ទលេខ: +855 (0) 23 219 814
សារអេឡិចត្រូនិច: maeday@un.org